*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

# សុន្ទរកថាគន្លឹះ

## របស់ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
## ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## ថ្លែងក្នុង
## ពិធីសម្ពោធជាផ្លូវការ «មូលនិធិអភិវឌ្ឍន៍ជំនាញ»
## ក្រោមប្រធានបទ ៖ អភិវឌ្ឍជំនាញ, អភិវឌ្ឍអាជីវកម្ម, អភិវឌ្ឍខ្លួនយើងទាំងអស់គ្នា»

ថ្ងៃ អង្គារ ៥ រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ត្រូវនឹងថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០២៤

សណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា

- ឯកឧត្តម **ហែម វណ្ណឌី** រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍;
- ឯកឧត្តម, លោកជំទាវ តំណាងក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល;
- ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី, តំណាងដៃគូអភិវឌ្ឍន៍, វិស័យឯកជន, គ្រឹះស្ថានបណ្តុះបណ្តាល, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ;
- សមាជិក-សមាជិកាទាំងអស់នៃអង្គពិធី, ជាទីមេត្រី !

*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានមកចូលរួម ជាអធិបតី និង ថ្លែងសុន្ទរកថាបើក ក្នុង «**ពិធីសម្ពោធជាផ្លូវការ មូលនិធិអភិវឌ្ឍន៍ជំនាញក្រោមប្រធានបទ ៖ អភិវឌ្ឍជំនាញ, អភិវឌ្ឍអាជីវកម្ម, អភិវឌ្ឍខ្លួនយើងទាំងអស់គ្នា**» ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះ **ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី, ជាតំណាងក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍, វិស័យឯកជន, គ្រឹះស្ថានបណ្តុះបណ្តាល, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិទាំងអស់** ដែលបានឆ្លៀតពេលដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងកម្មវិធី ដ៏មានសារៈសំខាន់ នាព្រឹកនេះ ។

ឆ្លៀតក្នុងឱកាសនេះ, ខ្ញុំសូមសម្តែងនូវការអបអរសាទរ និង ការកោតសរសើរដ៏ស្មោះ ចំពោះក្រុមប្រឹក្សាបរធនបាល និង អង្គភាពប្រតិបត្តិ នៃមូលនិធិអភិវឌ្ឍន៍ជំនាញ ព្រមទាំងភាគីពាក់ព័ន្ធទាំងអស់, ទាំងវិស័យសាធារណៈ និង វិស័យឯកជន, ដែលបានខិតខំរួមគ្នាបំពេញភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម រហូតសម្រេចបាននូវសមិទ្ធផលជាច្រើន ក្នុងការកៀរគរ, ការគ្រប់គ្រង និង ការបែងចែកធនធាន ដើម្បីពង្រឹងគុណភាព និង ពង្រីកវិសាលភាពនៃការបណ្តុះបណ្តាលជំនាញ ស្របទៅនឹងតម្រូវការនៃវិស័យឯកជន តាមរយៈការពង្រឹង និង ការពង្រីកភាពជាដៃគូយុទ្ធសាស្រ្ត រវាងរដ្ឋ និង ឯកជន សំដៅចូលរួមដោះស្រាយបញ្ហាកង្វះជំនាញ ក្នុងរយៈពេល ៥ ឆ្នាំកន្លងទៅ, ដូច **ឯកឧត្តមបណ្ឌិត ផាន់ ផល្លា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានក្រុមប្រឹក្សាបរធនបាលនៃមូលនិធិអភិវឌ្ឍន៍ជំនាញ បានគូសរំលេច នៅមុននេះបន្តិច ។ បន្ថែមលើនេះ, ខ្ញុំក៏សូមវាយតម្លៃខ្ពស់ និង ថ្លែងអំណរគុណផងដែរ ចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់, ជាពិសេស ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលបានផ្តល់ការគាំទ្រ, ទាំងផ្នែកបច្ចេកទេស និង ហិរញ្ញប្បទាន, ចាប់តាំងពីដំណាក់កាលដំបូងនៃការបង្កើតគម្រោងសាកល្បង នៃយន្តការគ្រប់គ្រងមូលនិធិអភិវឌ្ឍន៍ជំនាញ ចាប់តាំងពីខែ មីនា ឆ្នាំ ២០១៨ ។

## *ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!*

ក្នុងរយៈពេល ២៥ ឆ្នាំ ចុងក្រោយនេះ, ក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាពពេញផ្ទៃប្រទេស ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បាននាំមកជូនប្រទេសជាតិ និង ប្រជាជន តាមរយៈ **នយោបាយឈ្នះ-ឈ្នះ**, កម្ពុជាបន្តសម្រេចបាននូវសមិទ្ធផលធំៗជាច្រើន ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង បានផ្លាស់ប្តូរមុខមាត់គួរ



តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

ជាទីមោទនៈ តាមរយៈការអនុវត្ត ប្រកបដោយជោគជ័យ នូវ **យុទ្ធសាស្ត្រត្រីកោណ និង យុទ្ធសាស្ត្រចតុកោណ, ទាំងបួនដំណាក់កាល**, ព្រមទាំងគោលនយោបាយ និង ផែនការយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀត ។ ខ្ញុំសូមគូសបញ្ជាក់ថា ការដាក់ចេញនូវគោល-នយោបាយត្រឹមត្រូវ, មុតស្រួច និង ទាន់ពេល បានជំរុញឱ្យកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងអត្រា ប្រមាណ ៧% ជាមធ្យម ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ មុនការមកដល់នៃជំងឺកូវីដ-១៩ រហូតបានប្រែក្លាយកម្ពុជា ពីប្រទេសចំណូលទាប ទៅជាប្រទេសចំណូលមធ្យមកម្រិតទាប កាលពីឆ្នាំ ២០១៥ ។ លើសពីនេះទៀត, ជាមួយនឹងមូលដ្ឋានសង្គម-សេដ្ឋកិច្ចដ៏រឹងមាំ ប្រកបដោយចីរភាព, បរិយាបន្ន, សមធម៌ និង ធន់នឹងវិបត្តិ, សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថា អាចសម្រេចបានកំណើន ក្នុងរង្វង់ ប្រមាណជាង ៥% ក្នុងឆ្នាំ ២០២៣ និង ត្រូវបានព្យាករណ៍ថា នឹងបន្តកើនឡើង ក្នុងរង្វង់ ប្រមាណ ៦% នៅឆ្នាំ ២០២៤ បន្ទាប់ពីទទួលរងនូវការបង្អាក់ដោយវិបត្តិជាសកលនៃជំងឺកូវីដ-១៩ និង ទោះបីជាកម្ពុជា ត្រូវបន្តជួបប្រឈមនឹងសភាព-ការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ក៏ដោយ ក្នុងនោះ រួមមាន ៖ ភាព-តានតឹងនៃស្ថានភាពភូមិសាស្ត្រនយោបាយ, ពិសេស សង្គ្រាម រវាងរុស្ស៊ី និង អ៊ុយក្រែន, ការប្រយុទ្ធរវាងអ៊ីស្រាអែល និង ហាម៉ាស់, និង កំណើនយឺតនៃសេដ្ឋកិច្ចសកល, ព្រមទាំងការថមថយនៃតម្រូវការនៅតាមបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មសំខាន់ៗ របស់កម្ពុជា ជាដើម ។

ច្បាស់ណាស់ថា, ក្នុងបរិការណ៍នេះ, កម្ពុជាត្រូវសម្របជាប្រចាំ តាមនិន្នាការប្រែប្រួលសកល ដែលទាមទារនូវការយកចិត្តទុកដាក់ខ្ពស់ ចំពោះការលើកកម្ពស់ភាព-ជាអ្នកដឹកនាំ និង សមត្ថភាពស្ថាប័នគ្រប់កម្រិត ដោយផ្សារភ្ជាប់នឹងការធានាបាន នូវគោលនយោបាយសមស្រប និង សមត្ថភាពអនុវត្តជាក់ស្តែង, លទ្ធផលការងារ និង ការទទួលខុសត្រូវ ដើម្បីឆ្លើយតបនឹងអាទិភាពសំខាន់ៗ នៅក្នុងដំណាក់កាលថ្មី រួមមានជាអាទិ៍៖ ការពង្រឹងអភិបាលកិច្ច; ការទ្រទ្រង់កំណើន និង ការធ្វើទំនើបកម្មសេដ្ឋកិច្ច; ការបង្កើតការងារ, ទាំងគុណភាព និង បរិមាណ; ការលើកស្ទួយវិស័យឯកជន និង សហគ្រិនភាព; ការកសាងមូលធនមនុស្ស ដោយផ្តោតជាពិសេស លើគុណភាពវិស័យអប់រំ, សេវាសុខាភិបាល និង សីលធម៌សង្គម; ការលើកស្ទួយសេវាគាំពារសង្គម និង

សុខុមាលភាពប្រជាជន, ជាពិសេស សម្រាប់គ្រួសារងាយរងហានិភ័យ និង ក្រុមជនងាយរងគ្រោះ; ការពង្រឹងគុណភាពនគរូបនីយកម្ម, ជាពិសេស ការកាត់បន្ថយគម្លាតរវាងទីក្រុង និង ជនបទ; ការពង្រឹងចីរភាពបរិស្ថាន និង ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ; ព្រមទាំងការជំរុញធ្វើបរិវត្តកម្មឌីជីថល, ទាំងក្នុងសង្គម និង សេដ្ឋកិច្ច ។

នៅក្នុងក្របខណ្ឌនៃទស្សនវិស័យនេះ និង ផ្អែកតាម **កម្មវិធីនយោបាយ** របស់ខ្លួន, រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា, ក្រោមការដឹកនាំដ៏ស្វាហាប់ និង ឈ្លាសវៃ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, ដែលជាអគ្គមគ្គុទ្ទេសក៍វ័យក្មេងដ៏ឆ្នើម និង ពោរពេញដោយសមត្ថភាព, ចំណេះដឹង និង ថាមពល, បានដាក់ចេញ នូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ដើម្បីកំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព, និង ចីរភាព**, ដោយផ្តោតជាសំខាន់លើរបៀបវារៈ ធានា «**ប្រសិទ្ធភាពសមិទ្ធកម្ម**» តាមរយៈការអនុវត្តអភិក្រម «**ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះកាត់**» និង អភិក្រម «**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**» ។ ជាមួយនឹង**បាវចនា ៥** គឺ៖ **កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និង ចីរ-ភាព** , **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** បានកំណត់យក **អាទិភាព គន្លឹះ ៥** គឺ៖ «**មនុស្ស, ផ្លូវ, ទឹក, ភ្លើង**, និង **បច្ចេកវិទ្យា**, ជាពិសេស គឺ **បច្ចេកវិទ្យាឌីជីថល**» សម្រាប់ឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មទី ៤ និង បរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និង សង្គមកម្ពុជា ក៏ដូចជាឆ្លើយតបនឹងតម្រូវការ ក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ដែលជាគ្រឹះ និង ជាមធ្យោបាយដ៏សំខាន់ នៃការសម្រេចបាននូវ **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** ។

ក្នុងស្មារតីនេះ, ដើម្បីរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់, ក្នុងពេលថ្មីៗនេះ, រាជរដ្ឋាភិបាល បានដាក់ចេញជាបន្តបន្ទាប់ នូវ ច្បាប់, គោលនយោបាយ និង យុទ្ធសាស្ត្រគាំទ្រ ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា មានជាអាទិ៍ ៖ **ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, ផែនទីបង្ហាញផ្លូវ ស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជា ឆ្នាំ ២០២២-២០៣៥, ផែនទីបង្ហាញផ្លូវ សម្រាប់ការអភិវឌ្ឍវិស័យយានយន្ត និង អេឡិកត្រូនិក, និង ផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និង កាត់ដេរកម្ពុជា ឆ្នាំ ២០២៣-២០២៧** ដើម្បីទាញយកប្រយោជន៍ជាអតិបរមា និង ជំរុញឱ្យអស់សក្តានុពល នូវប្រភពបច្ចុប្បន្ន

និង ប្រភពថ្មីនៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ក្នុងគោលដៅបង្កើត និង បង្កើនការងារដែលមានតម្លៃបន្ថែមខ្ពស់ និង ចាប់យកឱ្យបាន នូវកាលានុវត្តភាពថ្មី ដែលកំពុងលេចឡើង ស្របនឹងនិន្នាការតំបន់ និង សកល ដើម្បីស្តារសេដ្ឋកិច្ច-សង្គម ឡើងវិញ ក្រោយវិបត្តិនៃជំងឺកូវីដ-១៩ និង ដើម្បីធានាចីរភាពនៃកំណើន ក្នុងរយៈពេលវែង ក៏ដូចជាត្រៀមខ្លួនសម្រាប់ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា និង ឆ្លើយតបទៅនឹងការ-ប្រែប្រួលនិម្មាបនកម្មសេដ្ឋកិច្ចសកល ផងដែរ ។

ដើម្បីសម្រេចគោលដៅខាងលើ ដោយជោគជ័យ តាមការរំពឹងទុក, ក្រសួង-ស្ថាប័នពាក់ព័ន្ធ បាន និង កំពុងខិតខំប្រឹងប្រែងពន្លឿន និង ពង្រឹងកម្មវិធីកែទម្រង់ និង ការអនុវត្តគោលនយោបាយ និង យុទ្ធសាស្ត្រគន្លឹះៗ របស់រាជរដ្ឋាភិបាល ប្រកបដោយស្មារតីបុរេ-សកម្ម, ការទទួលខុសត្រូវ និង ការបំពេញបន្ថែមគ្នាទៅវិញទៅមក ។ ជាក់ស្តែង, ក្រសួងអប់រំ យុវជន និង កីឡា បាន និង កំពុងប្រឹងប្រែងលើកកម្ពស់គុណភាពសិក្សា ចាប់ពីថ្នាក់មត្តេយ្យ ដល់ឧត្តមសិក្សា, ខណៈក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បាន និង កំពុងបន្តជំរុញការអនុវត្ត **គោលនយោបាយជាតិ ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ឆ្នាំ ២០១៧-២០២៥** ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ សំដៅពង្រឹងគុណភាព និង ភាពឆ្លើយតបនៃការបណ្តុះបណ្តាលជំនាញ ឱ្យបានសមស្របទៅនឹងតម្រូវការទីផ្សារការងារជាក់ស្តែងបច្ចុប្បន្ន និង ទៅអនាគត ។

មិនតែប៉ុណ្ណោះ, កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២៣, **សម្តេចមហាបវរ-ធិបតី ហ៊ុន ម៉ាណែត** ក៏បានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នូវ **កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និង បច្ចេកទេស ដល់យុវជនមកពីគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យ នៅទូទាំងប្រទេស** និង **កម្មវិធីរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព តាមរបបភាគទានដោយស្ម័គ្រចិត្ត** ដែលជាការសបញ្ជាក់ឱ្យឃើញអំពីសារៈសំខាន់ និង អាទិភាពខ្ពស់នៃការអភិវឌ្ឍមូលធនមនុស្ស នៅក្នុងរបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ។ បន្ថែមពីនេះ, ការដាក់ចេញនូវ **កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និង បច្ចេកទេស ដល់យុវជនមកពីគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស** ដោយមិនបង់ថ្លៃសិក្សា និង ទទួលបាននូវប្រាក់ឧបត្ថម្ភប្រចាំខែ ចំនួន ២៨ ម៉ឺនរៀល គឺជាវិធានការបង្រួមវិសមភាពសេដ្ឋកិច្ចមួយប្រកបដោយប្រសិទ្ធភាព និង បរិយាបន្ន ដោយឈរលើអាទិភាពគន្លឹះ ទី ១៖ **មនុស្ស** និង គោលដៅយុទ្ធសាស្ត្រ

*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

ទី ៣៖ **សមធម៌** នៃ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** សំដៅសម្រេចឱ្យបាន នូវគោលដៅកាត់បន្ថយភាពក្រីក្រ ឱ្យចុះមកនៅ ក្នុងអត្រាទាបជាង ១០% និងបន្តខិតខំទាញទម្លាក់អត្រានៃភាពក្រីក្រ ឱ្យស្ថិតនៅក្នុងកម្រិតអប្បបរមា ។ កម្មវិធីនេះនឹងធ្វើឱ្យយុវជន មកពីគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យ មានជីវភាពប្រសើរឡើង ដោយរក្សាបាននូវស្ថិរភាពការងារ, កំណើនផលិតភាព, ប្រាក់ចំណូលសមរម្យ, លក្ខខណ្ឌការងារល្អ និង ការចាកផុតពីបន្ទាត់នៃភាពក្រីក្រ, ព្រមទាំងចូលរួមចំណែកបំពេញបន្ថែមគ្នា ក្នុងការឈានឆ្ពោះទៅសម្រេចបាន នូវបាវចនា ទាំង ៥ នៃ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ៖ កំណើន**, **ការងារ**, **សមធម៌**, **ប្រសិទ្ធភាព**, **និង ចីរភាព** ។

## *ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!*

សេដ្ឋកិច្ចកម្ពុជា កំពុងស្ថិតនៅលើវិថីនៃការផ្លាស់ប្តូរ ពីឧស្សាហកម្មអតិពលកម្មមកជាឧស្សាហកម្មផ្អែកលើជំនាញ និង បន្តឈានទៅអភិវឌ្ឍជាឧស្សាហកម្មទំនើបដែលផ្អែកជាសំខាន់ លើមូលដ្ឋានបច្ចេកវិទ្យា និង ចំណេះដឹង ។ ស្ថិតក្នុងបរិការណ៍នេះ, ការអភិវឌ្ឍជំនាញ ដើរតួនាទីកាន់តែសំខាន់ ក្នុងការលើកកម្ពស់សមត្ថភាព, ភាព-ប្រកួតប្រជែង និង កម្រិតជីវភាពរបស់ប្រជាពលរដ្ឋកម្ពុជា ក៏ដូចជាបំពេញតម្រូវការដ៏ធំធេងនៃកម្លាំងពលកម្មជំនាញ, ទាំងកម្រិតទាប, មធ្យម, និង ខ្ពស់, ឱ្យត្រូវនឹងតម្រូវការរបស់វិនិយោគិន, ទាំងគុណភាព និង បរិមាណ ។ ការណ៍នេះ ទាមទារឱ្យមានការចូលរួមយ៉ាងសកម្ម និង ក្នុងស្មារតីបុរេសកម្ម ពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់, ទាំងផ្នែកផ្គត់ផ្គង់ និង ផ្នែកដែលមានតម្រូវការ, ជាពិសេស វិស័យឯកជន, ដើម្បីរួមកម្លាំងជាធ្លុងមួយដែលមានលក្ខណៈប្រទាក់ក្រឡា និង បំពេញឱ្យគ្នាទៅវិញទៅមក ក្នុងគោលដៅសម្រេចបាន នូវគោលដៅយុទ្ធសាស្ត្រដែលរាជរដ្ឋាភិបាល បានដាក់ចេញ ។

ក្នុងស្មារតីបុរេសកម្ម និង ឆ្លើយតបនឹងការទទូចស្នើសុំពីដៃគូពាក់ព័ន្ធ, ជាពិសេស វិស័យឯកជន និង ដៃគូអភិវឌ្ឍន៍, រាជរដ្ឋាភិបាលបានធ្វើការសិក្សា និង វាយតម្លៃពីស្ថានភាពតម្រូវការ និង ការផ្គត់ផ្គង់ នៅក្នុងប្រព័ន្ធអេកូឡូស៊ីជំនាញ ជាមួយដៃគូអភិវឌ្ឍន៍, វិស័យឯកជន និង ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដោយផ្អែកលើនិន្នាការ និង និយាមជាអន្តរជាតិ និង ក្នុងតំបន់ ដោយគួបផ្សំនឹងបរិបទកម្ពុជាផ្ទាល់ ផងដែរ ។ ជាលទ្ធផល, រាជរដ្ឋាភិបាល

បានផ្ដួចផ្ដើមបង្កើត និង អនុវត្តគម្រោងសាកល្បងនៃយន្តការគ្រប់គ្រង មូលនិធិអភិវឌ្ឍន៍ជំនាញនេះ កាលពីខែ មីនា ឆ្នាំ ២០១៨ ក្នុងគោលបំណងធ្វើតេស្តសាកល្បងនូវយន្តការថ្មី ដែលមានលក្ខណៈនវានុវត្តន៍ ដើម្បីកៀរគរ, គ្រប់គ្រង និង បែងចែកធនធាន, ទាំងហិរញ្ញវត្ថុ និង មិនមែនហិរញ្ញវត្ថុ, សំដៅចូលរួមដោះស្រាយបញ្ហាកង្វះហិរញ្ញប្បទាន (Funding Gap) និង បញ្ហាកង្វះជំនាញ (Skills Gap) ក្នុងគោលបំណងពង្រឹងគុណភាព និង ពង្រីកវិសាលភាពនៃការអភិវឌ្ឍជំនាញ ឱ្យត្រូវនឹងតម្រូវការរបស់វិស័យឯកជន និង ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម តាមរយៈយន្តការចែករំលែកថ្លៃ និង ការចូលរួមបណ្ដុះបណ្ដាលដោយផ្ទាល់ ពីសំណាក់វិស័យឯកជន ។

បន្ទាប់ពីត្រូវបានអនុវត្ត អស់រយៈពេល ៥ ឆ្នាំកន្លងទៅ ដោយទទួលបានទំនុកចិត្តខ្ពស់ ពីក្រសួង-ស្ថាប័នពាក់ព័ន្ធ, វិស័យឯកជន និង ដៃគូអភិវឌ្ឍន៍, រាជរដ្ឋាភិបាល បានសម្រេចប្រែក្លាយគម្រោងសាកល្បងនេះ ទៅជាស្ថាប័នអចិន្ត្រៃយ៍ ដែលមានលក្ខណៈជាបរធនបាល (Trust Fund) ក្រោមឈ្មោះថា **«មូលនិធិអភិវឌ្ឍន៍ជំនាញ»**, ហៅកាត់ថា **ម.អ.ជ.** ឬ SDF, តាមរយៈអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០២៣ ដែលមានក្រុមប្រឹក្សាបរធនបាល ជាតំណាងមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ និង វិស័យឯកជន និង មានអង្គភាពប្រតិបត្តិដឹកនាំច្បាស់លាស់ ដោយមាននាយកប្រតិបត្តិមួយរូប ដឹកនាំក្រុមការងារ ទទួលបន្ទុកបំពេញកិច្ចការប្រចាំថ្ងៃដោយផ្ទាល់ ជាមួយវិស័យឯកជន និង ដៃគូពាក់ព័ន្ធ ដែលមានតម្រូវការជំនាញ ។

ខ្ញុំក៏សូមគូសបញ្ជាក់បន្ថែមថា មូលនិធិអភិវឌ្ឍន៍ជំនាញ (**ម.អ.ជ.**) គឺជាយន្តការបំពេញបន្ថែម លើកិច្ចប្រឹងប្រែង របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដោយ **ម.អ.ជ.** ដើរតួនាទីជាថ្នាល ក្នុងការទាក់ទាញឱ្យផ្នែកដែលមានតម្រូវការជំនាញ, ពោលគឺ វិស័យឯកជន, ចាប់ដៃគ្នា និង បង្កើតកិច្ចសហការជាមួយផ្នែកផ្គត់ផ្គង់, ពោលគឺ គ្រឹះស្ថានបណ្ដុះបណ្ដាលដែលមានគុណភាព, ដើម្បីដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្មជំនាញ, ទាំងបរិមាណ និង គុណភាព, សំដៅឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ទាំងក្នុងបច្ចុប្បន្ន និង ទៅអនាគត ។

ផ្អែកលើបទពិសោធន៍ ៥ ឆ្នាំកន្លងមកនេះ, **ម.អ.ជ.** បានលើកទឹកចិត្ត និង ផ្ដល់ការគាំទ្រ, ទាំងផ្នែកបច្ចេកទេស និង ហិរញ្ញវត្ថុ, ដែលអនុញ្ញាតិឱ្យគ្រឹះស្ថានបណ្ដុះបណ្ដាល, ទាំងរដ្ឋ ឯកជន និង អង្គការមិនមែនរាជរដ្ឋាភិបាល, មានលទ្ធភាពពង្រឹង និង ពង្រីក

*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

កិច្ចសហប្រតិបត្តិការ ជាមួយវិស័យឯកជន ក្នុងការរៀបចំ និង ការអនុវត្តកម្មវិធីបណ្តុះ-បណ្តាល ដែលត្រូវនឹងតម្រូវការទីផ្សារការងារជាក់ស្តែង ក៏ដូចជាការទាក់ទាញ និង ការ-ជំរុញការវិនិយោគ ក្នុងវិស័យអាទិភាពនានា របស់រាជរដ្ឋាភិបាល រួមមាន ៖ វិស័យទេសចរណ៍, វាយនភណ្ឌ និង កាត់ដេរ, ឱសថ, យានយន្ត, អេឡិចត្រូនិក, និង សំណង់ជាដើម ។

## *ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!*

ឆ្លៀតក្នុងឱកាសដ៏វិសេសនេះ, ជាទិសដៅទៅមុខ សំដៅរួមចំណែកពង្រឹងប្រសិទ្ធ-ភាព និង ស័ក្តិសិទ្ធភាពការងារបន្ថែមទៀត, ខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួន ដល់មូលនិធិអភិវឌ្ឍន៍ជំនាញ ក៏ដូចជាក្រសួង-ស្ថាប័ន, ដៃគូអភិវឌ្ឍន៍ និង វិស័យឯកជនដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងការអភិវឌ្ឍជំនាញ ដូចខាងក្រោម៖

**ទី១**-ក្រសួង-ស្ថាប័ន និង ភាគីពាក់ព័ន្ធទាំងអស់, ទាំងស្ថាប័នរដ្ឋ, វិស័យឯកជន និង ដៃគូអភិវឌ្ឍន៍, ត្រូវបន្តចូលរួម និង សហការឱ្យអស់ពីលទ្ធភាព, **ដើម្បីក្លាយជាកម្លាំងចលកររួមដ៏ធំមួយ** សម្រាប់របៀបវារៈនៃការអភិវឌ្ឍមូលធនមនុស្សនៅកម្ពុជា ប្រកបដោយចំណេះ, ជំនាញ, ឥរិយាបថ, និង ក្រមសីលធម៌វិជ្ជាជីវៈ ស្របតាម **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ក្រោមការដឹកនាំដ៏ឈ្លាសវៃ និង ប៉ិនប្រសព្វខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ។

**ទី២**-មូលនិធិអភិវឌ្ឍន៍ជំនាញ ត្រូវបន្តលើកកម្ពស់គុណភាពសេវា និង ប្រសិទ្ធភាពនៃការគ្រប់គ្រង និង ការបែងចែកធនធានរបស់មូលនិធិ សំដៅលើកកម្ពស់ទំនុកចិត្ត និងការចូលរួមរបស់ដៃគូពាក់ព័ន្ធ ក្នុងការអភិវឌ្ឍជំនាញ ដែលជាតម្រូវការពិតប្រាកដ របស់វិស័យឯកជន ។

**ទី៣**-មូលនិធិអភិវឌ្ឍន៍ជំនាញ ត្រូវចាប់ផ្តើមគិតគូរ និង សិក្សាពីម៉ូដែលហិរញ្ញ-ប្បទាន សម្រាប់រយៈពេលមធ្យម និង រយៈពេលវែងទៅមុខ សំដៅធានាឱ្យបាននូវប្រសិទ្ធភាព និង និរន្តរភាពនៃហិរញ្ញប្បទាន សម្រាប់គាំទ្រការអភិវឌ្ឍជំនាញ ដល់ប្រជា-ពលរដ្ឋកម្ពុជា ឱ្យត្រូវនឹងតម្រូវការ របស់វិស័យឯកជន ផង និង តម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ផង ។

*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

**ទី៤**-មូលនិធិអភិវឌ្ឍន៍ជំនាញ ត្រូវបន្តរៀបចំកម្មវិធីថ្មីបន្ថែមទៀត ដើម្បីឆ្លើយតប នឹងតម្រូវការរបស់វិស័យឯកជន ក៏ដូចជាគាំទ្រដល់គោលនយោបាយគន្លឹះៗ របស់រាជរដ្ឋាភិបាល ព្រមទាំងសិក្សាពីតម្រូវការជំនាញបច្ចុប្បន្ន និង អនាគត ដែលចាំបាច់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ។

**ទី៥**-មូលនិធិអភិវឌ្ឍន៍ជំនាញ ត្រូវបន្តធ្វើឌីជីថលូបនីយកម្មបន្ថែម លើប្រតិបត្តិការរបស់ខ្លួន ដើម្បីបង្កើនប្រសិទ្ធភាព, ពង្រឹងគុណភាព និង ធានាតម្លាភាព, គណនេយ្យភាព និង ទំនុកចិត្តនៃការគ្រប់គ្រង និង ការបែងចែកមូលនិធិ ។

មុននឹងបញ្ចប់, ជាថ្មីម្តងទៀត, ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី, ជាថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន និង តំណាងដៃគូអភិវឌ្ឍន៍, វិស័យឯកជន, គ្រឹះស្ថានបណ្តុះបណ្តាល, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិទាំងអស់, ដែលបានអញ្ជើញចូលរួមក្នុងកម្មវិធី នាព្រឹកនេះ ។ ខ្ញុំក៏សូមថ្លែងអំណរគុណជាពិសេស ដល់ Human Resource Development Corporation (HRD Corp) មកពីម៉ាឡេស៊ី និង Singapore National Employers Federation (SNEF) មកពីសិង្ហបុរី សម្រាប់ការចូលរួមចែករំលែកបទពិសោធន៍នៃប្រទេសរៀងខ្លួន ដែលជាធាតុចូលដ៏សំខាន់ សម្រាប់មូលនិធិអភិវឌ្ឍន៍ជំនាញ ក្នុងការពង្រឹង និង ការពង្រីកកម្មវិធីគាំទ្រ ទៅអនាគត ។

នៅទីបញ្ចប់, ខ្ញុំសូមជូនពរ ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រីទាំងអស់ ប្រកបដោយពុទ្ធពរ និង ពរ ទាំង ៥ ប្រការ គឺ៖ អាយុ, វណ្ណៈ, សុខៈ, ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបើក **កម្មវិធីសម្ពោធជាផ្លូវការ មូលនិធិអភិវឌ្ឍន៍ជំនាញ ក្រោមប្រធានបទ ៖ អភិវឌ្ឍជំនាញ, អភិវឌ្ឍអាជីវកម្ម, អភិវឌ្ឍខ្លួនយើងទាំងអស់គ្នា** ចាប់ពីពេលនេះតទៅ ៕

***សូមអរគុណ!***